**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងព្រហ្មទណ្ឌលេខ:៣៣២

ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៧

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ១៨ (ច)

ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការ*

ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨

*ដោយមានសមាសភាពជំនុំជម្រះ៖*

១-លោក [redacted] *ចៅក្រមជំនុំជម្រះ*

២-លោកស្រី [redacted] *តំណាងអយ្យការ*

៣-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*<u>ដើម្បីធ្វើការជំនុំជម្រះលើជនជាប់ចោទ:</u>*

១-ឈ្មោះ: [redacted] ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតភូមិកណ្តាល ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទីកន្លែងសព្វថ្ងៃនៅភូមិកណ្តាល ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៧) ។

២-ឈ្មោះ: [redacted] ភេទប្រុស អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិកណ្តាល ឃុំលេខ២ ស្រុកទឹកផុសខេត្ត ខេត្តកំពង់ឆ្នាំង ទីកន្លែងសព្វថ្ងៃភូមិកណ្តាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ: [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

៣-ឈ្មោះ: [redacted] ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីកន្លែងសព្វថ្ងៃភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ: [redacted] (ស) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន ។

ត្រូវជាប់ចោទពីបទៈការទិញគ្រឿងញៀនដើម្បីលក់ដោយខុសច្បាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ: [redacted]



Scanned by CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១២និង០០នាទី ស្ថិតនៅភូមិកណ្តាល សង្កាត់ ប្បារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានករណី ការទិញគ្រឿងញៀនដើម្បីលក់ដោយខុសច្បាប់ និងប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយឈ្មោះ: [redacted] ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ: [redacted] ភេទប្រុស និងឈ្មោះ [redacted] អាយុ ២៦ឆ្នាំ តាមចម្លើយរបស់ឈ្មោះ: [redacted] បានរៀបរាប់ថា: កន្លងមកឈ្មោះ: [redacted] បានទិញគ្រឿងញៀនពីឈ្មោះ: [redacted] ចំនួន ១០ដង ម្តង ១កញ្ចប់ និងធ្លាប់ ទិញពីឈ្មោះ: [redacted] ប្រហែលជា ១០ដងដែរ ក្នុងទិញនោះ: [redacted] និងទុកប្រើប្រាស់ខ្លួនឯងផង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២៦៦៨ /១៧ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៥៨៧ /១៧ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២០៩ /១៨ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

### នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១១ ព្រឹក ខ្លួនត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនដោយសារខ្លួនបានទៅទិញគ្រឿងញៀនឲ្យឈ្មោះ [redacted] ដើម្បីយកមកជក់ជាមួយគ្នា ដោយខ្លួនទិញពីឈ្មោះ: [redacted] ចំនួន ១០០.០០០(មួយរយពាន់) រៀល ចំនួន មួយកញ្ចប់ ពីមុនខ្លួនទិញពីឈ្មោះ [redacted] ចំនួន ០២ ដងមកហើយ មុនឈ្មោះ [redacted] ជាប់ពន្ធនាគារ ខ្លួនចេះជក់គ្រឿងញៀនរយៈពេលយូរហើយ នៅក្នុងរឿងនេះខ្លួនសូមសារភាពថាខ្លួនពិតជាបានលក់គ្រឿងញៀនទៅឲ្យអ្នកដទៃប្រាកដមែន ដោយខ្លួនទទួលស្គាល់ចម្លើយដែលឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្លួនពិតជាធ្លាប់លក់គ្រឿងញៀនឲ្យទៅឈ្មោះ: [redacted] ពិតប្រាកដមែន ដោយក្នុងនោះខ្លួនធ្លាប់លក់ឲ្យតែម្តងប៉ុណ្ណោះ តម្លៃ ៥០.០០០(ហាសិបពាន់) រៀល ខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀនដែរ ។

-ចម្លើយមន្ត្រីនគរបាលឈ្មោះ: [redacted] បានឆ្លើយថា: នៅថ្ងៃកើតហេតុ ក្រោយទទួលដំណឹងថាមានការចរាចរណ៍គ្រឿងញៀន ខ្លួនក៏ប្រើប្រាស់កម្លាំង ដោយទិញពីឈ្មោះ [redacted] បានពីដង ដោយនៅថ្ងៃចុងក្រោយទិញបានចំនួន ១០០.០០០(មួយរយពាន់) រៀល ក្រោយឃាត់ខ្លួនបានឈ្មោះ: [redacted] សារភាពថាបានទិញគ្រឿងញៀនពីឈ្មោះ: [redacted] និងឈ្មោះ: [redacted]

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ: [redacted] ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទា



Scanned by CamScanner

ទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា: អំពីអង្គហេតុកូនក្តីខ្លួនបានត្រូវឃាត់ខ្លួន ពាក់ព័ន្ធនឹងការទិញគ្រឿងញៀនដើម្បីលក់ គឺកូនក្តីខ្លួនគ្រាន់តែទិញគ្រឿងញៀនទៅប្រើប្រាស់តែប៉ុណ្ណោះ ដោយឈ្មោះ: [redacted] ទៅទិញដោយប្រើកូនក្តីខ្លួនដើម្បីប្រើប្រាស់ ម្យ៉ាងទៀតកូនក្តីខ្លួនពេលសមត្ថកិច្ចឃាត់ខ្លួនគឺបានប្រើប្រាស់គ្រឿងញៀន ត្រឹមតែមួយកញ្ចប់តូចប៉ុណ្ណោះ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ពាក់ព័ន្ធនឹងការចោទប្រកាន់មានន័យថាពុំត្រឹមត្រូវឡើយ ព្រោះពេលឃាត់ខ្លួនកូនក្តីខ្លួនគ្រាន់តែប្រើប្រាស់ប៉ុណ្ណោះ ហើយការប្រើប្រាស់កម្លាំងពុំមានឯកសារបញ្ជាក់ពីតំណាងអយ្យការផង សូមឲ្យចៅក្រមមេត្តាជួយឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted]បានសំណូមពរចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ: [redacted] បានសំណូមពរចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:</u>

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៨៧ /១៧ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបញ្ជូនជនជាប់ចោទ ១-ឈ្មោះ [redacted] ២-ឈ្មោះ: [redacted]-ឈ្មោះ: [redacted]មកតុលាការដើម្បីជំនុំជម្រះពីបទ ការទិញគ្រឿងញៀនដើម្បីលក់ដោយខុសច្បាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] ថា: កាលពីថ្ងៃកើតហេតុ ខ្លួនពិតជាបានទៅទិញគ្រឿងញៀនចំនួន ១០០.០០០(មួយរយពាន់) រៀល ដោយទទួលការពឹងពាក់ពីឈ្មោះ[redacted]ខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ: [redacted]និងឈ្មោះ[redacted]នៅក្នុងរឿងនេះខ្លួនសូមសារភាពថាខ្លួនពិតជាបានលក់គ្រឿងញៀនទៅឲ្យអ្នកដទៃប្រាកដមែន ដោយខ្លួនទទួលស្គាល់ចម្លើយដែលឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌



Scanned by CamScanner

៣-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ថា: ខ្លួនធ្លាប់លក់គ្រឿងញៀនឲ្យឈ្មោះ [redacted]ត ម្តងប៉ុណ្ណោះ ក្នុងតម្លៃ ៥០.០០០(ហាសិបពាន់) រៀល ។

៤-ចម្លើយជនជាប់ចោទឈ្មោះ [redacted]ា: អវត្តមាននាពេលសវនាការ ។

៥-ចម្លើយមន្ត្រីនគរបាលថា: ខ្លួនបានប្រើកម្លាំងទៅទិញគ្រឿងញៀនពីឈ្មោះ [redacted] បានពីរដង ក្រោយឃាត់ខ្លួនបាន ទើបឈ្មោះ [redacted]សារភាពថាបានទិញគ្រឿងញៀនពីឈ្មោះ [redacted]និង ឈ្មោះ [redacted]

៧-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។ការប្តឹងសុំរបស់តំណាងអយ្យការ តុលាការអាចពិចារណាបាន ព្រោះបើតាមអង្គហេតុជនជាប់ចោទទាំងពីរបានឆ្លើយសារភាពថាបានទិញគ្រឿងញៀន ដើម្បីយកទៅលក់ឲ្យអ្នកដទៃពិតប្រាកដមែន គួបផ្សំពេលប្រតិបត្តិការសមត្ថកិច្ចឃាត់ខ្លួនបានពេលកំពុងតែជក់ផងដែរ គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៨-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា: អំពីអង្គហេតុកូនក្តីខ្លួនបានត្រូវឃាត់ខ្លួន ពាក់ព័ន្ធនឹងការទិញគ្រឿងញៀនដើម្បីលក់ គឺកូនក្តីខ្លួនគ្រាន់តែទិញគ្រឿងញៀនទៅប្រើប្រាស់តែប៉ុណ្ណោះ ដោយឈ្មោះ [redacted]ទៅទិញដោយប្រើកូនក្តីខ្លួនដើម្បីប្រើប្រាស់ ម្យ៉ាងទៀតកូនក្តីខ្លួនពេលសមត្ថកិច្ចឃាត់ខ្លួនគឺបានប្រើប្រាស់គ្រឿងញៀន ត្រឹមតែមួយកញ្ចប់តូចប៉ុណ្ណោះ មាត្រា ៣៨ នៃវិធានមន្ទុញ្ញវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ពាក់ព័ន្ធនឹងការចោទប្រកាន់មានន័យថាពុំត្រឹមត្រូវឡើយ ព្រោះពេលឃាត់ខ្លួនកូនក្តីខ្លួនគ្រាន់តែប្រើប្រាស់ប៉ុណ្ណោះ ហើយការប្រើប្រាស់កម្លាំងពុំមានឯកសារបញ្ជាក់ពីតំណាងអយ្យការផង សូមឲ្យចៅក្រមមេត្តាជួយឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។ ការស្នើសុំរបស់មេធាវី តុលាការមិនអាចពិចារណាបានឡើយ ព្រោះបើតាមអង្គហេតុជនជាប់ចោទបានឆ្លើយសារភាពថាពិតជាបានលក់គ្រឿងញៀនទៅអ្នកដទៃ ស៊ីសង្វាក់ទៅនឹងចម្លើយសមត្ថកិច្ចដែលប្រើប្រាស់កម្លាំងទៅទិញពីជនជាប់ចោទបានពីរដងផងដែរ ម្យ៉ាងទៀតក្នុងការប្រើប្រាស់កម្លាំងទោះមិនមានឯកសារបញ្ជាក់ ប៉ុន្តែមានការអនុញ្ញាតដោយផ្ទាល់មាត់ពីតំណាងអយ្យការ តុលាការយល់ថាក្នុងការចោទប្រកាន់នេះមិនមែនជាវិមតិសង្ស័យឡើយ ព្រោះជនជាប់ចោទបានឆ្លើយសារភាព បូកផ្សំនឹងប្រតិបត្តិការបង្ក្រាបរបស់សមត្ថកិច្ចផងដែរ ។

៩-ឆ្លងកាត់សវនាការ ការពិភាក្សាដេញដោល ចម្លើយជនជាប់ចោទ ចម្លើយមន្ត្រីជំនាញ ការប្តឹងសុំរបស់តំណាងអយ្យការ ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿងតុលាការពិចារណាឃើញថាជនជាប់ចោទទាំងបីពិតជាបានជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ព្រោះបើតាមការសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]ានបញ្ជាក់ថាបានលក់គ្រឿងញៀនទៅឲ្យអ្នកដទៃដោយទិញពីជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]ាងទៀតពេលប្រតិបត្តិការជនជាប់ចោទក៏កំពុងប្រើប្រាស់គ្រឿងញៀនផងដែរ ដោយអំពើរបស់ជនជាប់ចោទទាំងបីនាក់ជាធាតុផ្សំក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។



Scanned by CamScanner

១០-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទៈ

១០.១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ។

១០.២-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៩ ឆ្នាំ ។

១០.៣-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៧ ឆ្នាំ ។

ពីបទៈជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១-វត្ថុតាងរឹបអូសៈ

១១.១-ទូរស័ព្ទដៃចំនួន ០១ គ្រឿង គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

១០.២-ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០១ កញ្ចប់ និងឧបករណ៍ជក់មួយចំនួន គប្បីតុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។

១២-យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីចៅក្រមជំនុំជម្រះចេញដីកាបង្គាប់ឲ្យចាប់ខ្លួនទៅលើជនជាប់ចោទឈ្មោះ [redacted] ។

១៣-ជនជាប់ចោទជានីតិជន ដែលមិនមានភស្តុតាងបញ្ជាក់ថាកើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បំផ្លាញដល់សុខភាពខ្លួនឯងផ្ទាល់ ប៉ះពាល់ដល់ជីវភាពគ្រួសារ និងឈានដល់ការបង្កការលំបាកជាច្រើនទៀតដល់សង្គមជាតិ ដែលកើតឡើងដោយសារធាតុឥទ្ធិពលនៃគ្រឿងញៀន ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទៈ

១.១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣ (បី) ឆ្នាំ ។

១.២-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣(បី) ឆ្នាំ ។

១.៣-ឈ្មោះ [redacted] ទប្រុស អាយុ ២៩ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣ (បី) ឆ្នាំ ។

ពីបទៈជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុតាងរឹបអូសៈទូរស័ព្ទដៃចំនួន ០១ គ្រឿង តុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ចំណែកថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០១ កញ្ចប់ តុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។

៣-បង្គាប់ឲ្យអាជ្ញាធរមានសមត្ថកិច្ចស្វែងរកចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]



Scanned by CamScanner

៨-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]

បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner